**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំត្រីមាសទី១ ឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងត្រីមាសទី១ ឆ្នាំ២០១៩នេះ តាមការកត់សម្គាល់ឃើញថាការងារបង្កបង្កើនផលស្រូវរដូវប្រាំងនៅទូទាំងប្រទេស បានបញ្ចប់ជាស្ថាពរហើយសម្រេចបានចំនួន ៥៩៦ ៤៨៣ហ.ត ស្មើនឹង១៣៣,២៩% នៃផែនការ ៤៤៧ ៥០០ហ.ត។ ការប្រើប្រាស់គ្រឿងយន្តសម្រាប់ការរៀបចំដីផលិតកម្មដំណាំស្រូវរដូវប្រាំងគឺស្មើនឹង៩៨,៩០% ធៀបនឹងការប្រើប្រាស់ដោយគោ-ក្របីមាន១,១០% រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផលក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសទី១ ឆ្នាំ២០១៩នេះគឺ បានរៀបចំសន្និបាតកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការរៀបចំកិច្ចប្រជុំសំខាន់ៗ ការទទួលជួបភ្ញៀវជាតិ-អន្តរជាតិ ការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសជាច្រើន រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំត្រីមាសទី១ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងត្រីមាសទី១ ឆ្នាំ២០១៩នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលបញ្ចប់ផ្នែកដាំដុះរដូវប្រាំងឆ្នាំ២០១៨-២០១៩

#### ១.១ ផលិតកម្មដំណាំស្រូវរដូវប្រាំង

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវប្រាំងគិតត្រឹមថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៩ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៦៣២ ៩០២ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៦ ៩៩៣ហ.ត និងដោយគ្រឿងយន្តមានចំនួន ៦២៥ ៩០៩ហ.ត លើសឆ្នាំមុនចំនួន ៧១ ៨៣៤ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ១៧២ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៥៩៦ ៤៨៣ហ.ត ស្មើនឹង១៣៣,២៩% នៃផែនការ ៤៤៧ ៥០០ហ.ត លើសឆ្នាំមុនចំនួន ៤៧ ៧២៨ហ.ត។

#### ១.២ ការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១៨-២០១៩

ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបានចំនួន ៤៧៨ ៨២៣ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ២ ១៥០ ១០៨តោន លើសឆ្នាំមុនចំនួន ៨៧៥ ៧២៦តោន។ ទិន្នផលគិតជាមធ្យម ៤,៤៩០តោន/ហ.ត។

#### ១.៣ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៨-២០១៩

-ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៣៨ ៨៤៤ហ.ត ស្មើនឹង១២២,៩៩% នៃផែនការ ៣១ ៥៨៤ហ.ត លើសឆ្នាំមុនចំនួន ៦ ១១៧ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៨៣ ៤៣៣ហ.ត ស្មើនឹង៧៨,១៨% នៃផែនការ ១០៦ ៧១៣ហ.ត តិចជាងឆ្នាំមុនចំនួន ៣៨ ៣៣០ហ.ត។

### ១.៤ ការនាំចេញអង្ករ

ក្នុងត្រីមាសទី១ ឆ្នាំ២០១៩នេះ ការនាំអង្ករចេញតាមច្រកចេញ-ចូលតែមួយគឺមានបរិមាណសរុបចំនួន ១៧០ ៨២១តោន ដែលមានការកើនឡើងចំនួន ៩ ៧០៦តោន (+៦%) ធៀបនឹងបរិមាណនាំចេញក្នុងត្រីមាសទី១ ឆ្នាំ២០១៨។ ការនាំចេញទៅកាន់ទិសដៅចំនួន ៣៩ប្រទេស ក្នុងនោះប្រទេសចិនលំដាប់ទី១ (៧៥ ២១៤តោន) ប្រទេសបារាំងលំដាប់ទី២ (២០ ០៥៨តោន) ប្រទេសហ្កាបុងលំដាប់ទី៣ (១២ ១២២តោន) ប្រទេសម៉ាឡេស៊ីលំដាប់ទី៤ (៩ ៤៧៣តោន) ប្រទេសប្រ៊ុយណេលំដាប់ទី៥ (៧ ៧៧០តោន) ប្រទេសវៀតណាមលំដាប់ទី៦ (៦ ៦៨៥តោន) ប្រទេសណេដឺឡែនលំដាប់ទី៧ (៤ ៥៦០តោន) ប្រទេសអេស្បាញលំដាប់ទី៨ (៤ ៣៨៣តោន) ប្រទេសអាល្លឺម៉ង់លំដាប់ទី៩ (៣ ៦៥២តោន) និងប្រទេសប៊ែលហ្សិកលំដាប់ទី១០ (៣ ៥៣៤តោន) ហើយបច្ចុប្បន្នក្រុមហ៊ុនដែលបាននាំចេញអង្ករមានចំនួន ៦៧ក្រុមហ៊ុន។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| លរ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តបានប្រចាំ៣ខែ (តោន) | បញ្ចេញលក់ប្រចាំ៣ខែ (តោន) |
|---|---|---|---|---|---|
| I.ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៦៧០ | ៨០១ | ៩៦ | ៥០ |
| សរុប I | | ៦៧០ | ៨០១ | ៩៦ | ៥០ |
| II. ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុនសុភក្តិនិកា អ៊ិនវេសមេនគ្រុប | ១២ ២០១ | ១៥ ០៧០ | ២ ៥៦៦ | ៣ ៣៦២ |
| ២ | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | ១ ១៩១ | ២ ១០៥ | ២៧៦ | ៣៣៦ |
| ៣ | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៥ ៦៣១ | ៨ ៤៤០ | ៧១៥ | ៩៥៥ |
| ៤ | ក្រុមហ៊ុន ស៊ីហ្វារ៉ាប់បើលីមីធីត (រតនគិរី) | ៧៩ | ២ ៧២៤ | ៦១០ | 0 |
| ៥ | ក្រុមហ៊ុនស៊ីហ្វវីសសស៍(ស្នួល) | ៣ ៨៥៩ | ៤ ៤០៦ | ៥៦១ | ៨០០ |
| ៦ | ក្រុមហ៊ុន ឡុង ស្រេង | ៣ ៣៤៣ | ៤ ១៨៧ | ៥៦៧ | ៤២០ |
| ៧ | ក្រុមហ៊ុន អានម៉ារ៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣ ៤១៨ | ៤ ៨៣៣ | ២៤២ | ២៥០ |
| ៨ | ក្រុមហ៊ុនអានម៉ារ៉ាឌីគ្រុប (ពាមជាំង របាសហែក) | ២ ០១០ | ៣ ៣២២ | ១២០ | ១០០ |
| ៩ | ក្រុមហ៊ុនក្រេក(ខេមបូឌា)ខូអិលធីឌី | ៤ ៣៥៩ | ៤ ៧៩៨ | ១ ៥២៦ | ១ ៤៧០ |
| សរុបII | | ៣៦ ០៩១ | ៤៩ ៨៨៥ | ៧ ១៨៣ | ៧ ៦៩៣ |
| III. ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៤៤ ៩២២ | ២២៤ ៥៦៧ | ១៦ ៩០០ | ១៦ ១០០ |
| ២ | ចម្ការកៅស៊ូគ្រួសារ | ១១៩ ៨៣៧ | ១៦១ ១០៣ | ២៤ ៦០០ | ២៤ ២០០ |
| សរុប III | | ១៦៤ ៧៥៩ | ៣៨៥ ៦៧០ | ៤១ ៥០០ | ៤០ ៣០០ |
| សរុប I + II + III | | ២០១ ៥២០ | ៤៣៦ ៣៥៦ | ៤៨ ៧៧៩ | ៤៨ ០៤៣ |

គួរកត់សម្គាល់ថាជ័រកៅស៊ូក្នុងខែមីនា ឆ្នាំ២០១៩នេះមានតម្លៃជាមធ្យម ១ ៣៦១ដុល្លារ/តោន។

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាយោបល់ឧស្សាហកម្ម និងពិធីបើកសម័យប្រជុំថ្នាក់ជាតិលើកទី៥២នៅប្រទេសសិង្ហបុរី
- ធ្វើតេស្តប្រៀបធៀបជាមួយក្រុមហ៊ុន សុភក្តិនិកា អ៊ិនវេសមេនគ្រុប ខូ.,អិលធីឌី ស្រុកសណ្តាន់ ខេត្តកំពង់ធំ

- វិភាគបរិមាណជ័រស្ងួត DRC ចម្ការពិសោធន៍នីមួយៗតាមវិធីសាស្ត្រឧបករណ៍មេត្រូឡាក់ និងតាមមន្ទីរពិសោធន៍ ចំនួន ៣ដង លើ១៤ចម្ការពិសោធន៍
- ត្រួតពិនិត្យការអូសក្រិតប្តូរផ្ទាំងមុខចៀរជ័រលើចម្ការពិសោធន៍ IRAE02 IRAE03 IRAE05 IRAE09 IRAE10 និង IRAE13
- ពិនិត្យតាមដានការសារប្រមូលផលទឹកជ័រតាមបច្ច័យនៃសារនីមួយៗនៅគ្រប់ឡូត៍ពិសោធន៍
- រៀបចំបើកចៀរជ័រដំបូងសម្រាប់ឡូត៍ពិសោធន៍ក្នុងស្ថានីយមួយឡូត៍គឺ IRAA10 លើផ្ទៃដីប្រមាណ ៦,០៦៣ហ.ត
- វាស់ទំហំដើមកៅស៊ូចំនួន ២ឡូត៍ពិសោធន៍លើផ្ទៃដីប្រមាណ ១១,៧៣ហ.ត
- រៀបចំ និងត្រួតពិនិត្យការប្តូរមុខចៀរជ័រឡូត៍ពិសោធន៍ IRAA03 IRAA04 IRAA05 និង IRAA08
- រក្សាទុកកូនកៅស៊ូចំនួន ១ប្លុកសម្រាប់ការបំបៅ Clone exchange
- ថែទាំថ្នាលបណ្តុះកូនកៅស៊ូឆ្នាំ២០១៩-២០២០
- បំបៅកូនកៅស៊ូរួចរាល់សម្រាប់ការត្រៀមដាំដុះឆ្នាំ២០១៩ គឺ Clone PMB1 និងដាំជួសកូនកៅស៊ូឆ្នាំ២០១៨
- ចុះទៅត្រួតពិនិត្យ និងប្រមូលទិន្នន័យគ្រប់ឡូត៍ពិសោធន៍ក្លូននៅចម្ការកៅស៊ូជប់ និងចម្ការកៅស៊ូក្រែក
- ចុះវាស់ទំហំដើមកៅស៊ូក្នុងឡូត៍ពិសោធន៍ក្លូននៅចម្ការកៅស៊ូជប់ ក្រែក និងចម្ការកៅស៊ូទ្រីភាពបឹងទន្លេម្រេចខេត្តព្រះវិហារ
- ចុះទៅក្រុមហ៊ុនចម្ការកៅស៊ូ SOCFIN-KCD នៅខេត្តមណ្ឌលគិរី ដើម្បីពិភាក្សា និងរៀបចំបើកមុខចៀរឡូត៍ពិសោធន៍។

## ៣ ផ្នែកកសិ-ឧស្សាហកម្ម

- បានរៀបចំប្រជុំគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្មស្តីពីការពិនិត្យពិភាក្សាអំពីរបាយការណ៍វឌ្ឍនភាព បញ្ហាប្រឈម និងទិសដៅអនុវត្តន៍បន្ត
- បានធ្វើការអប់រំផ្សព្វផ្សាយចំនួន ២លើក ស្តីពីការការពារការពុលមេតាណុល និងសារធាតុគីមីផ្សេងៗទៀតនៅក្នុងផលិតផលស្រាស
- បានសហការជាមួយ KOICA ដើម្បីរៀបចំសិក្ខាសាលាស្តីពីការសិក្សាស៊ីជម្រៅលើឧស្សាហកម្មទី៤ក្នុងវិស័យកសិកម្ម
- បានសហការរៀបចំនិងធ្វើបទបង្ហាញស្តីពីផលិតផលកសិកម្មតាមកិច្ចសន្យាក្នុងវគ្គបណ្តុះបណ្តាលពីការលើកកម្ពស់ការយល់ដឹងលម្អិតពីដំណើរការ និងលក្ខខណ្ឌផ្សេងៗក្នុងការអនុវត្តកិច្ចសន្យាផលិតកម្មដំឡូងមី
- បានចុះសម្របសម្រួលលើកិច្ចសន្យាផលិតកម្មកសិកម្ម និងចូលរួមជាអធិបតីក្នុងពិធីចុះហត្ថលេខាចំនួន២លើកក្នុងពិធីចុះកិច្ចសន្យាផលិតកម្មកសិកម្ម ដើម្បីផ្គត់ផ្គង់ស្ករត្នោតពីសំណាក់សហគមន៍កសិកម្មឈូកសាមគ្គីមានជ័យនៅខេត្តកំពង់ធំ និងសហគមន៍កសិកម្មត្នោតខេត្តកំពង់ស្ពឺ
- បានចូលរួមប្រជុំសហការជាមួយសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាដើម្បីធ្វើការសិក្សាអំពីកសិ-ឧស្សាកម្មសម្រាប់ដាក់គម្រោងជូនភ្នាក់ងារសហប្រតិបត្តិការអាល្លឺម៉ង់
- បានចូលរួមសិក្ខាសាលាស្តីពីការអនុវត្តកិច្ចព្រមព្រៀងកសិកម្ម (AoA) និងកិច្ចព្រមព្រៀង SPS ក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងការជំរុញការនាំចេញផលិតផលកសិកម្មនៅខេត្តកំពត
- បានរៀបចំ និងពិនិត្យឡើងវិញនូវវិធីសាស្ត្រសម្រាប់វិភាគរកសមាសធាតុ អាស៊ូត (N) ផូស្វ័រ (P) និងប៉ូតាស្យូម (K) នៅក្នុងផលិតផលកសិកម្ម និងចំណីអាហារ
- បានវិភាគរកសមាសធាតុ អាស៊ូត (N) ផូស្វ័រ (P) នៅក្នុងជីកំប៉ុស្ត
- ពិសោធន៍សាកល្បងការផ្សំអាហារបំប៉នសម្រាប់បណ្តុះមេផ្សិតម្ជូល
- បានវិភាគរកសមាសធាតុ Protein នៅក្នុងអាហារផ្អាប់ចំនួន ២១ប្រភេទ
- បានចុះប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ទាក់ទងនឹងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានៅខេត្តក្រចេះ
- បានចុះបណ្តុះបណ្តាលកសិករស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តតាកែវ។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារព្រៃឈើ

- បានចេញសេចក្តីប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ១កន្លែងមានផ្ទៃដីទំហំ ១ ២៧៥,៤៦ហ.ត ក្នុងខេត្តកំពង់ធំ និងចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ពីងប្រង់ក្លង់ប៉េសចូ នៅខេត្តមណ្ឌលគិរីមានផ្ទៃដីទំហំ ១ ១០៤ ហ.ត

- យល់ព្រមជាគោលការណ៍លើផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ២កន្លែងគឺ សហគមន៍ព្រៃឈើព្រៃតាយ៉ង់ និងសហគមន៍ព្រៃឈើត្រពាំងក្បាលខ្មោច ខេត្តកំពង់ធំមានផ្ទៃដីសរុបទំហំ ១ ៤៣៥,៦៩ហ.ត

- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តជូនក្រុមហ៊ុន និងអ្នកស្នើសុំសរុបចំនួន ១២គ្រឿង និងយានយន្តសរុបចំនួន ១២គ្រឿង

- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ៤ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ៥នាក់ ដែលមានឈើហ៊ុបមូលចំនួន ២២ ៦០០ម៣ ឈើប្រណីតចំនួន ១០៨ម៣ ឈើជ្រុងចំនួន ២ ៧៩០ម៣ កូនឈើចំនួន ៣៤ ៤០០ដើម អុសចម្រុះចំនួន ២៦ ៤០៩ស្ទែរ និងជ័រទឹកចំនួន ១៩២តោន។

### ៤.២ ការងារអភិរក្សសត្វព្រៃ

- បានចុះបង្ក្រាបការជួញដូរសត្វព្រៃចំនួន ២លើក នៅខេត្តមណ្ឌលគិរី និងខេត្តស្ទឹងត្រែង ដោយរឹបអូសបានសាច់សត្វជ្រូកព្រៃចំនួន ២៤គ.ក្រ សាច់ឈ្លូសចំនួន ១២គ.ក្រ និងអន្សងរស់ចំនួន ២ក្បាល

- បានចុះធ្វើការផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការជួញដូរសត្វព្រៃ និងសារសំខាន់សត្វព្រៃចំនួន ២លើក នៅខេត្តមណ្ឌលគិរី និងខេត្តកំពង់ធំ

- បានចុះប្រមូលសំណាក (ឈាម ទឹកមាត់ លាមក និងជាលិកា) ពីពពួកថនិកសត្វតូចៗ និងសត្វប្រចៀវ ពីខេត្តកំពត ព្រះសីហនុ កោះកុង កំពង់ស្ពឺ តាកែវ មណ្ឌលគិរី និងខេត្តរតនគិរី ចំនួន ១៩១ក្បាល ស្មើនឹង១ ៩៧២សំណាក ត្រូវជា ៣០ប្រភេទ ក្នុងនោះមានប្រចៀវចំនួន ២០ប្រភេទ ថនិកសត្វតូចៗ (កណ្តុរ និងសត្វកកេរ) ចំនួន ១០ប្រភេទ។

### ៤.៣ បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន ៦ ដែលមានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៧ទីតាំង នៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង មានស្វាក្តាមចំនួន ៥៥ ០៩៧ក្បាល ក្នុងនោះកូនកើតរយៈពេល ៣ខែមានចំនួន ៤ ០០៧ក្បាល

- សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩ នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៥៤៤ក្បាល (បក្សីចំនួន ៥៥ប្រភេទ ថនិកសត្វចំនួន ៤១ប្រភេទ និងល្មូនចំនួន ១៣ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ១៧៨ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ៧៩ក្បាល

- ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងសត្វព្រៃគ្រប់ប្រភេទទៅព្រៃធម្មជាតិវិញចំនួន ២១០ក្បាល ដោយឡែកគម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ ក្រុម ល្បាតសហគមន៍ចំនួន ៣០នាក់ បានដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ០៥គឺ តំបន់អារ៉ែង ឆាយរាប តំបន់ស្តារក្រពើ ស្ទឹងជាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់) ព្រមទាំងបានដោះលែងក្រពើភ្នំពូជសុទ្ធទៅក្នុងដែនជម្រកធម្មជាតិនៅស្ទឹងខៀវ ខេត្តកោះកុង ចំនួន ២០ក្បាល

- ជួសជុលលុបផ្លូវសំបុកមាន់ក្រាលក្រួសក្រហមប្រវែង ៨១៦ម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃទំហំ ៦,៦៨ហ.ត។

### ៤.៤ ការងារដាំដើមឈើ

- បាននិងកំពុងថែទាំចម្ការឈើចាស់ ចម្ការពូជឈើឡូតិ៍បង្ហាញកសិ-រុក្ខកម្មទំហំ ៩៨០ហ.ត នៅក្នុងខេត្តកំពង់ធំ សៀមរាប ព្រះសីហនុ និងខេត្តស្វាយរៀង និងបណ្តុះកូនឈើចំនួន ១០១ ៥០០ដើម និងដាំឈើលើផ្ទៃដីទំហំ ១៥២ហ.ត ក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំ និងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរថ្ម ខេត្តព្រះសីហនុ

- បានបណ្តុះកូនឈើគ្រប់ប្រភេទចំនួន ១១៧ ៨៣៧ដើម ប្រគេនកូនឈើជូនព្រះសង្ឃ និងចែកប្រជាពលរដ្ឋសរុបចំនួន ២៣ ៤៤១ដើម

- សហការជាមួយរដ្ឋបាលព្រៃឈើមូលដ្ឋានដើម្បីចុះត្រួតពិនិត្យ តាមដាន វាស់វែង និងប្រគល់-ទទួលផល ឈើពីចម្ការឈើដាំរបស់រដ្ឋដើម្បីប្រមូលចំណូលចូលថវិកាជាតិនៅខេត្តតាកែវចំនួន ៧០២ស្ទែរឌុប៦០៥ គិតជាទឹកប្រាក់សរុបចំនួន ១៤ ០៥២ដុល្លារ។

### ៤.៥ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩នេះ សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ១៩៥ករណី ដោយពិន័យអន្តរការណ៍ចំនួន ១១៧ករណី និងបញ្ជូនទៅតុលាការចំនួន ៧៨ករណី

- ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើបានចាប់ឃាត់ និងដកហូតរួមមាន ឈើមូល-ជ្រុងសរុបចំនួន ៩៦ម៣ ឈើអារចំនួន ៣៤២ម៣ គ្រាក់ក្រញូងចំនួន ២ម៣ សត្វព្រៃចម្រុះប្រភេទចំនួន ១ ៤៦៧ក្បាល និងទម្ងន់ ៨០គ.ក្រ និងសំណុំរឿងកាប់រានដីព្រៃចំនួន ៦ករណី មានដីព្រៃចំនួន ២២៦ហ.ត ត្រូវបានបញ្ជូនទៅតុលាការ។

### ៤.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- បានចុះពិនិត្យដល់ទីតាំងជាក់ស្តែងតាមលក្ខណៈបច្ចេកទេសជូនក្រុមហ៊ុន និងសិប្បកម្មអារ-កែច្នៃឈើចំនួន ១៥កន្លែង ដែលបានស្នើសុំបង្កើតរោងម៉ាស៊ីនអារ-កែច្នៃឈើចំនួន ៤កន្លែង និងពន្យារសុពលភាពរោងម៉ាស៊ីនអារ-កែច្នៃឈើចំនួន ១១កន្លែង

- ក្រុមហ៊ុនចំនួន៥បានធ្វើការនាំចេញផលិតផលគ្រឿងសង្ហារឹម និងរានទេវតាពីឈើនាំចូល និងឈើអារកែច្នៃទៅក្រៅប្រទេសមានចំនួន២៩៨ម៣ និងផលិតផលជ័រទឹកចំនួន ៥៦តោន។ ក្រុមហ៊ុនចំនួន២ បានធ្វើការនាំចូលឈើអារកែច្នៃ (MDF) ពីប្រទេសចិន និងប្រទេសកុងហ្គោមានចំនួន ២៥០ម៣ និងផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញចំនួន៣ក្រុមហ៊ុនមានផលិតផលឈើកែច្នៃចំនួន ៧០ម៣ និងផលិតផលជ័រទឹកចំនួន៩០តោន ព្រមទាំងបានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលផល-អនុផលព្រៃឈើចំនួន២ក្រុមហ៊ុន ដែលមានឈើកែច្នៃចំនួន៤១២ម៣។

### ៤.៧ ការងារចំណូលព្រៃឈើ

- សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩នេះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន ៩ ៣០៤ ៧៦៩ ២៩០រៀល និង៦៩ ២៨១ដុល្លារ។

## ៥ ផ្នែកផលិតកម្ម និងបសុពេទ្យបាល

**៥.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្តៈ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសួនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ។

### ៥.២ ការងារបសុពេទ្យបាល

- **លទ្ធផលត្រួតពិនិត្យ បង្ក្រាបបទល្មើសសត្វ និងផលិតផលមានដើមកំណើតពីសត្វ៖** ក្នុងត្រីមាសទី១ ឆ្នាំ២០១៩ នេះ រាជធានី-ខេត្តចំនួន២៤ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ២៧ ៥៤៨លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តសរុបចំនួន ១០២ករណី ក្នុងនោះឃាត់ចាប់ចំនួន ៩ករណី និងត្រួតពិនិត្យមានលិខិតអនុញ្ញាតត្រឹមត្រូវចំនួន ៩៣ករណី ព្រមទាំងបានណែនាំដល់ក្រុមហ៊ុន និងអាជីវករដែលដឹកជញ្ជូនសត្វរស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញដើម្បីការពារការឆ្លងរាលដាលនៃជំងឺផ្សេងៗ។
- **ការងារសុខភាពសាធារណៈ៖** ចុះបង្កើនការយល់ដឹងការអនុវត្តល្អក្នុងសត្តឃាតដ្ឋានតាមលក្ខណៈបច្ចេកទេសនៅខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ ពោធិ៍សាត់ បន្ទាយមានជ័យ ប៉ៃលិន និងខេត្តកំពត។
- **ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចុះធ្វើការផ្សព្វផ្សាយជំងឺឆ្លងសត្វនៅខេត្តចំនួន ៨រួមមាន ខេត្តកែប កំពត កំពង់ស្ពឺ តាកែវ រតនគិរី មណ្ឌលគិរី ក្រចេះ និងខេត្តស្ទឹងត្រែង ដោយរៀបចំកិច្ចប្រជុំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមសត្វ និងជំងឺឆ្លងសត្វ។
- **ការងារនីតិកម្មនិងវិវាទ៖**

- សម្រេចបានគោលការណ៍ណែនាំស្តីពីការដាក់ឱ្យប្រើប្រាស់ និងអនុវត្តសៀវភៅកំណត់ត្រាសម្រាប់គ្រប់ប្រតិបត្តិការដែលពាក់ព័ន្ធនឹងបសុឱសថ និងចំណីសត្វ

- ប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិតលាយផ្សំ ការវេចខ្ចប់ជាថ្មី ការសន្និធិ ការផ្គត់ផ្គង់ ចែកចាយ ការលក់ដុំលក់រាយបសុឱសថ កំពុងដាក់ប្រជុំពិភាក្សាបន្ត។

### ៥.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០២ក្បាល ក្នុងនោះគោប្រាម៉ាន់កាត់ ៣០ក្បាល កូនគោបៅដោះ ៣៥ក្បាល គោកំផែងសែន ៣៧ក្បាល។ ដោយឡែក នៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប ២០២ក្បាល។

• ការងារស្រាវជ្រាវបសុព្យាបាលៈ ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ៣ ៨៦២វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។

## ៦ ផ្នែកជលផល

### ៦.១ អាជីវកម្មនេសាទ

#### ៦.១.១ នេសាទទឹកសាប

- ដាយត្រីអនុវត្តបានចំនួន ២ ៣៧០តោន ស្មើនឹង១៩,៧៥% នៃផែនការ១២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ ថយចុះចំនួន ២២០តោន
- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ៧០ ៣០០តោន ស្មើនឹង២០,៣៨% នៃផែនការ ៣៤៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ១ ៣២០តោន
- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ១៩ ១០០តោន ស្មើនឹង១៣,១៧% នៃផែនការ ១៤៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ១០០តោន។

#### ៦.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ២៥ ៨៥០តោន ស្មើនឹង២៣,៥០% នៃផែនការ ១១០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ២០០តោន។

### ៦.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ៤៣ ២២២តោន ស្មើនឹង១៤,៤១% នៃផែនការ ៣០០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ៧ ២០៤តោន
- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ៣០ ៥៥០ក្បាល ស្មើនឹង១០,១៨% នៃផែនការ ៣០០ ០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ៥០ក្បាល
- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ៤៨ ០០០ ០០០កូន ស្មើនឹង២០% នៃផែនការ ២៤០ ០០០ ០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួនប្រមាណ ១ ០០០ ០០០កូន។

### ៦.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តបានចំនួន ១៨ ៦៥០តោន ស្មើនឹង២២,៧៤% នៃផែនការ ៨២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ១០០តោន
- ផលនេសាទសមុទ្រអនុវត្តបានចំនួន ២ ៦៣០តោន ស្មើនឹង២៩,២២% នៃផែនការ ៩ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ៦០តោន
- ការផលិតទឹកត្រីអនុវត្តបានចំនួន ១២ ១០០ ០០០លីត្រ ស្មើនឹង២២% នៃផែនការ ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ១ ២០០ ០០០លីត្រ។

### ៦.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩នេះ សំណុំរឿងបទល្មើសជលផលមានចំនួន ៦១៩ករណី ប្រៀបធៀបក្នុងឆ្នាំ២០១៨ ថយចុះចំនួន ២២៩ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ៥៧៧ករណី និងសមុទ្រចំនួន ៤២ករណី។
- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមានៈ របាំងស្បៃមុងនិងសាច់អួនប្រវែង ២១១ ២៤៨ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន ៧ ១៣១មាត់ បង្គោល/ចម្រឹងចំនួន ៩៨ ៦៤៦ដើម សម្រាប់ទំហំ ២៥ ៤៦១ម៉ែត្រក្រឡា លបកែច្នៃចំនួន ១ ៨៥០គ្រឿង ឧបករណ៍ឆក់ត្រីចំនួន ១៤១គ្រឿង និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន ៨ ៨៩៨គ.ក្រ។

### ៦.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់អនុវត្តបានចំនួន ២ ៤៥០តោន ស្មើនឹង១៦,៣៣% នៃផែនការ ១៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ ថយចុះចំនួន ១៥០តោន
- ផលនេសាទកែច្នៃអនុវត្តបានចំនួន ១ ០០០តោន ស្មើនឹង២០% នៃផែនការ ៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ ថយចុះចំនួន ១០០តោន។

### ៦.៦ ការប្រមូលថវិកា

ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលក្នុងត្រីមាសទី១ ឆ្នាំ២០១៩ ចំនួន ២០៧ ២១៣ ០៧២រៀល ស្មើនឹង៦,៨១% នៃផែនការ ៣ ០៤៣ ០០០ ០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ ថយចុះចំនួន ៦២២ ០៨១ ៩២៨រៀល។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានចុះប្រមូលបន្ថែមសំណាកផ្កាអ័រគីដេនិងដំណាំផ្សេងទៀតចំនួន ១៥សំណាក និងបន្តការអភិរក្សពូជដំណាំចំនួន ៣៨ប្រភេទ ដែលរួមមានស្រូវចំនួន ៦ ៧៣១បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន ៣៧ប្រភេទ សរុបចំនួន ២ ០៩៦បញ្ជីក/សំណាក សរុបទាំងអស់មានចំនួន ៨ ៨២៧បញ្ជីក/សំណាក។ បានដាំវាយតម្លៃនិងកំណត់លក្ខណៈសំណាកត្រសក់ស្រូវ ម្ទេស និងល្ពៅចំនួន ៥៣,៥៨ និង ២៤សំណាករៀងគ្នា

- បានធ្វើពិសោធន៍ចំនួន ៤២ប្រភេទ នៅ១៦៥កន្លែងដែលនៅក្នុងនោះមានពិសោធន៍បន្សាំពូជលើស្រែកសិករ និងស្រែបង្ហាញចំនួន ៨៥កន្លែង។ ធ្វើទិវាស្រែចំនួន ៤លើក មានកសិករចូលរួមចំនួន ២៣១នាក់ និងបើកវគ្គបណ្ដុះបណ្ដាលចំនួន ១វគ្គដែលមានអ្នកចូលរួមចំនួន ២៦នាក់

- បានដឹកនាំនិស្សិតសរសេរសារណាបរិញ្ញាបត្រចំនួន៦នាក់ និងបណ្ឌិត១នាក់

- បានបោះពុម្ពឯកសារឡើងវិញចំនួន ១០ ៦២០ច្បាប់ និងបែងចែកឯកសារចំនួន ៣ ៥២០ច្បាប់។ អ្នកប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យាតាមរយៈគេហទំព័រ http://www.cardi.org.kh មានចំនួនសរុប ១០៤ ៧២១នាក់

- បានចូលរួមសន្និបាតប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងចែកគ្រាប់ពូជសុទ្ធគ្រឹះសរុបចំនួន ៤៧៥គ.ក្រ នៃពូជស្រូវផ្កាមាលតី ដែលក្រសួងទើបបញ្ចេញជូនកសិករកាលពីឆ្នាំមុន ជូនដល់អគ្គនាយកដ្ឋានកសិកម្មចំនួន ១០០គ.ក្រ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង២៥រាជធានី-ខេត្ត ដោយក្នុងមួយខេត្តទទួលបានចំនួន ១៥គ.ក្រ សម្រាប់ផលិតគ្រាប់ពូជចំណាត់ថ្នាក់ និងផ្សព្វផ្សាយបន្ត

- បានចូលរួមសន្និបាតនិងកិច្ចប្រជុំនានានៅក្នុងនិងក្រៅប្រទេសចំនួន ៩លើក ហើយទទួលជួបភ្ញៀវជាតិនិងអន្តរជាតិនៅវិទ្យាស្ថានចំនួន ៦លើក ដែលមានភ្ញៀវសរុបចំនួន ១២នាក់។

## ៨ ផ្នែកនីតិកម្មកសិកម្ម

### ៨.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្ដល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មបានចំនួន ៥២ក្រុមហ៊ុន សរុបចំនួន ៦៤១មុខ
- ផ្ដល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន ៥៥ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៨ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៩ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤ក្រុមហ៊ុន។

### ៨.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ២៧ក្រុមហ៊ុន សរុបចំនួន ១៨៥សំណាក។

### ៨.៣ ការងារបណ្ដុះបណ្ដាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្ដីពីបទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្មនៅខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តសៀមរាប

- បានបើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈវគ្គទី៨នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបន្ទាយមានជ័យ។

### ៨.៤ ការងារអនុវត្តច្បាប់

- បានរៀបចំសិក្ខាសាលាអញ្ជើញក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្ម ចូលរួមប្រជុំណែនាំអំពីនីតិវិធីនៃការប្រកាសប្រតិវេទន៍ស្ដីពីការនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២លើក

- ចុះពិនិត្យការនាំចូលសម្ភារកសិកម្ម និងផ្ដល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន៣៧ក្រុមហ៊ុន

- ធ្វើការពិន័យអន្តរការណ៍ចំពោះក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មពុំបានប្រកាសប្រតិវេទន៍ស្ដីពីការនាំចូលសម្ភារកសិកម្មចំនួន ៥ក្រុមហ៊ុន។

## ៩ ផ្នែករដ្ឋបាល

- ក្នុងត្រីមាសទី១ ឆ្នាំ២០១៩នេះ បានទទួលលិខិតសរុបចំនួន ២ ៤៩១ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ១ ១២១ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៩៣៨ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ៤៣២ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៣ ០៧១ច្បាប់

ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ១៦៦ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ៨៩ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានរៀបចំសន្និបាតសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ វេទិកាកសិកម្ម និងវេទិកាកៅស៊ូប្រចាំឆ្នាំ២០១៨។

## ១០ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៦ ៧០៧នាក់ ក្នុងនោះស្រីចំនួន ១ ៦១០នាក់ ស្មើនឹង ២៤% រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៨៧៦នាក់ ក្នុងនោះស្រីចំនួន ៨៤១នាក់ ស្មើនឹង ២៩,៣៣%
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ៣ ៨៣១នាក់ ក្នុងនោះស្រីចំនួន ៧៦៩នាក់ ស្មើនឹង ២០,០៧%

- បានតែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន ១៨៦នាក់ (ស្រី៥២នាក់)

- បានចេញប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន ៨នាក់ (ស្រី១នាក់) ក្នុងនោះ បោះបង់ចោលការងារចំនួន ១នាក់ លាឈប់ពីការងារចំនួន ៣នាក់ និងមរណភាពចំនួន ៤នាក់ (ស្រី១នាក់)

- បានចេញប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន ៣នាក់ ផ្ទេរចូលក្នុងក្រសួងចំនួន ៧នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន ២នាក់

- បានចេញប្រកាសដាក់ឲ្យមន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើមចំនួន ៤នាក់

- បានចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារមានចំនួន ៣៦នាក់ (ស្រី១២នាក់) ក្នុងនោះ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន ២១នាក់ (ស្រី៨នាក់) ច្បាប់ព្យាបាលជំងឺចំនួន ២នាក់ និងច្បាប់សម្រាកមាតុភាពចំនួន ១៣នាក់

- បានចេញប្រកាសដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សមានចំនួន ៨នាក់

- បានចេញប្រកាសឲ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញមានចំនួន ១៧នាក់ (ស្រី២នាក់)

- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ២១៨នាក់ (ស្រី៤៥នាក់) ក្នុងនោះ៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លីនិងមធ្យមសរុបចំនួន ១៦៥នាក់ (ស្រី៣៣នាក់)
  + ការបណ្តុះបណ្តាលក្រៅប្រទេសសរុបចំនួន ៥៣នាក់ (ស្រី១២នាក់) មាន៖ ការបណ្តុះបណ្តាលរយៈពេលខ្លីនិងមធ្យមចំនួន ៥១នាក់ (ស្រី១១នាក់) និងរយៈពេលវែងចំនួន ២នាក់។

## ១១ មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- តាមដាន និងតំហែទាំគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តឲ្យដំណើរការរលូនជាប្រចាំ

- ចុះតាមដានការអនុវត្ត ការប្រើប្រាស់ និងបង្ហាញមុខងារប្រើប្រាស់ថ្មីៗលើគេហទំព័ររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តឧត្តរមានជ័យ កំពង់ឆ្នាំង និងខេត្តបាត់ដំបង

- សកម្មភាពការងារក្នុងប្រព័ន្ធព័ត៌មានភូមិសាស្ត្រកសិកម្ម ទទួលបានលទ្ធផល ១.រៀបចំទិន្នន័យផែនទីរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបន្ទាយមានជ័យ ស្វាយរៀង កណ្តាល មណ្ឌលគិរី និងខេត្តរតនគិរី ដើម្បីទុកផ្ទៀងផ្ទាត់ក្នុងការចុះប្រមូលយកទិន្នន័យ ២.រៀបចំតារាងប្រមូលទិន្នន័យ គ្រោះមហន្តរាយ ដើម្បីត្រៀមបញ្ចូលទៅក្នុងប្រព័ន្ធ ៣.កែសម្រួលផ្ទាំងបង្ហាញខាងមុខ និងរៀបចំគេហទំព័រព័ត៌មានភូមិសាស្ត្រកសិកម្មទៅក្នុងម៉ាស៊ីនមេថ្មី ដើម្បីឲ្យមានដំណើរការប្រសើរជាងមុន

- ចុះបណ្តុះបណ្តាលការប្រើប្រាស់ ផ្សព្វផ្សាយអំពីគេហទំព័របណ្ណាល័យកសិកម្ម និងពិនិត្យអំពីការរៀបចំបណ្ណាល័យរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង និងខេត្តតាកែវ ដើម្បីបង្ហាញពីការធ្វើបច្ចុប្បន្នភាពបណ្ណាល័យកសិកម្មអេឡិចត្រូនិកបម្រើផលប្រយោជន៍លើការសិក្សាស្រាវជ្រាវដល់មន្ត្រីរាជការ សាធារណជនទូទៅ សិស្ស និស្សិត

- ជំរុញការផ្សព្វផ្សាយឯកសារកសិកម្ម សេចក្តីជូនដំណឹង សារាចរណែនាំ សេចក្តីសម្រេច ប្រកាស និងលិខិតបទដ្ឋានគតិយុត្ត ឲ្យបានទូលំទូលាយលើបណ្តាញផ្សព្វផ្សាយសង្គម (ហ្វេសប៊ុក) និងគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានសម្របសម្រួលធ្វើលិខិតស្នើសុំប្រាក់បេសកកម្មក្រៅប្រទេសជូនថ្នាក់ដឹកនាំ និងមន្ត្រីចំនួន ៣១ករណី
- បានសម្របសម្រួលស្នើសុំគោលការណ៍ចាត់មន្ត្រី និងថ្នាក់ដឹកនាំចូលរួមប្រជុំក្រៅប្រទេសចំនួន ៩ករណី
- រៀបចំលិខិតសុំគោលការណ៍ទៅ**សម្តេចនាយករដ្ឋមន្ត្រី** ដើម្បីធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ានចំនួន ១ករណី
- ធ្វើលិខិតជូនឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សុំជួយបញ្ជូនគម្រោងព័ត៌មានផ្កាយរណបសម្រាប់គ្រប់គ្រងធនធានដីកសិកម្មកម្ពុជាក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីប្រទេសកូរ៉េសម្រាប់ឆ្នាំ២០១៩
- សុំអន្តរាគមន៍បញ្ជូនគម្រោងស្តីពីការអភិវឌ្ឍជលផលតំបន់ឆ្នេរសមុទ្រកម្ពុជាជូនទៅប្រទេសចិន
- សុំផ្តល់កិច្ចអន្តរាគមន៍សម្របសម្រួលជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈប្រតិភូចូលរួមទស្សនកិច្ចនៅស្នាក់ការកណ្តាលនៃវិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិ (IRRI) នៅប្រទេសហ្វីលីពីន
- បានរៀបចំប្រជុំត្រៀមរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ផែនការយុទ្ធសាស្ត្រជូនអង្គការមិនមែនរាជរដ្ឋាភិបាលទាំងអស់។

## ១៣ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- បន្តចុះពិនិត្យ និងវាយតម្លៃវត្ថុតាងបទល្មើសជលផល អនុផលព្រៃឈើសម្រាប់ដាក់ដេញថ្លៃ ឬពិគ្រោះថ្លៃនៅរាជធានី-ខេត្ត
- ចុះពិនិត្យការអនុវត្តការប្រមូលចំណូលឆ្នាំ២០១៨ ជំរុញប្រមូលចំណូលឆ្នាំ២០១៩ និងលើកទិសដៅការប្រមូលចំណូលឆ្នាំ២០២០ ទៅកាន់ខេត្តឧត្តរមានជ័យ បន្ទាយមានជ័យ ស្ទឹងត្រែង និងខេត្តក្រចេះ
- បានរៀបចំលិខិតអន្តរាគមន៍ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីសំណើសុំគោលការណ៍ធានាចំណាយឥណទានថវិកាជំពូកទី២១ចំនួន ៧ ៧៦០ ០០០ ០០០រៀលសម្រាប់គាំទ្រដំណើរការគម្រោងកម្មវិធីជំរុញផលិតកម្មស្បៀងឆ្នាំ២០១៩
- បានទទួលបង្កាន់ដៃបង់ប្រាក់ថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន៥
- ចុះពិនិត្យ និងវាយតម្លៃជាក់ស្តែងសម្រាប់គណនាថ្លៃសម្បទានដីសេដ្ឋកិច្ចត្រូវបង់ចូលថវិការដ្ឋចំនួន៨ក្រុមហ៊ុន
- ចុះពិនិត្យផ្ទៀងផ្ទាត់តារាងប្រៀបធៀបទ្រព្យសម្បត្តិកើនឡើង ថយចុះប្រចាំឆ្នាំ២០១៨ តាមដាន និងជំរុញការអនុវត្តនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង រតនគិរី សៀមរាប បន្ទាយមានជ័យ ព្រះវិហារ និងខេត្តត្បូងឃ្មុំ។

## ១៤ ផ្នែកសវនកម្មផ្ទៃក្នុង

- បានរៀបចំគម្រោងផែនការចំណាយតាមនីតិវិធីលទ្ធកម្មប្រចាំឆ្នាំ២០១៩
- ធ្វើតារាងស្ថិតិមធ្យោបាយដឹកជញ្ជូនរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងឆ្នាំ២០១៨
- ធ្វើរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីប្រចាំត្រីមាសទី១ ឆ្នាំ២០១៩
- បានធ្វើសំណើសុំជម្រះបញ្ជីរជ្ជទេយ្យបុរេប្រទានជំ១ វគ្គ១ និងវគ្គទី២
- ក្នុងត្រីមាសទី១ ឆ្នាំ២០១៩ បានចុះធ្វើសវនកម្មចំនួន ១០សវនដ្ឋាន និងតាមដានអនុសាសន៍សវនកម្មគ្រាមុនចំនួន១សវនដ្ឋាន ដោយរកឃើញលទ្ធផលសវនកម្មនិងផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបានទាន់ពេលវេលា។

## ១៥ ផ្នែកផែនការនិងស្ថិតិ

- បានចូលរួមប្រជុំអន្តរក្រសួងចំនួន ៨៩លើក ចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន ១៨ លើក និងចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន ៩លើក
- ស្នើគ្រប់អង្គភាពក្រោមឱវាទក្រសួង ដើម្បីរៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំ រំកិល២០២០-២០២២ និងរៀបចំសិក្ខាសាលាស្តីពី យន្តការ នីតិវិធី និងរៀបចំបញ្ចូល ព័ត៌មាន ទិន្នន័យ នៃកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស) ៣ឆ្នាំរំកិល២០២០-២០២២
- បញ្ជូនតារាងសូចនាករ គោលដៅសូចនាករនៃគម្រោងថវិកាកម្មវិធីឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អនុញ្ញាតជាគោលការណ៍ឲ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាលចំនួន ២០ ៧៣៤គ.ក្រ

- ចុះតាមដានត្រួតពិនិត្យ វាយតម្លៃលើការអនុវត្តគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ច (ឆ្នាំ២០១៨) ក្នុងខេត្តទាំង១៩ ដែលមានដីសម្បទានសេដ្ឋកិច្ច

- ចុះប្រមូលព័ត៌មាន និងទិន្នន័យពាក់ព័ន្ធការដាំដុះដំណាំ និងចិញ្ចឹមសត្វ ក្នុងគម្រោងវិនិយោគ សម្បទានដីសេដ្ឋកិច្ច នៅខេត្តក្រចេះ កំពង់ចាម កំពង់ធំ កំពង់ស្ពឺ កំពត ត្បូងឃ្មុំ សៀមរាប រតនគិរី មណ្ឌលគិរី ព្រះវិហារ ស្ទឹងត្រែង កោះកុង និងខេត្តព្រះសីហនុ

- ឆ្លើយតបទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លើករណីកាត់ដីចេញពីគម្របព្រៃ ឈើឆ្នាំ២០០២ និងធ្វើអនុបយោគដីជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិសមូហភាពជូនសហគមន៍ជនជាតិដើមភាគតិច ៣សហគមន៍នៅខេត្តរតនគិរី

- បានចុះណែនាំស្ទង់ទិន្នផលស្រូវរដូវប្រាំងឆ្នាំ២០១៨-២០១៩

- ទទួលសំណាកចំនួន ៣ ៦០០សំណាកសម្រាប់រដូវប្រាំង សម្រេចតាមផែនការ ១០០% ឆ្នាំ២០១៨-២០១៩

- បានចុះអង្កេតស្ទង់ទិន្នផលស្រូវប្រាំងខេត្តត្បូងឃ្មុំ និងខេត្តតាកែវ

- បានចូលរួមប្រជុំ ពិគ្រោះយោបល់ស្ដីពីការរៀបចំធ្វើអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩

- បានចុះតាមដានការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៨-២០១៩ ដោយសហការជាមួយមន្ត្រីស្ថិតិថ្នាក់ខេត្ត ស្រុក

- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្ដាហ៍បីដង និងតម្លៃលក់រាយម្ដងក្នុងសប្ដាហ៍ តាមបណ្ដាទីផ្សារសំខាន់ៗទីតាំងប្រមូលទិញកន្លែងលក់ដុំ ផលិតផលក្នុងបណ្ដារាជធានី-ខេត្តចំនួន ២៥

- ផ្ដល់ទិន្នន័យជារៀងរាល់ខែដល់ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អង្គការកម្មវិធីស្បៀងអាហារពិភពលោក (WFP) អង្គការកសិកម្មស្បៀងអាហារ(FAO) និស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង

- បានរៀបចំសិក្ខាសាលាស្ដីពី ទស្សនទានទីផ្សារកសិកម្ម នៅខេត្តកំពង់ចាម ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៦៣នាក់

- ចូលរួមប្រជុំពិភាក្សាលើការវិនិយោគបង្កើតរោងចក្រកែច្នៃម្ហូបអាហារ (សាច់មាន់ ទា និងគ្រឿងក្នុងជ្រូក)

- ចូលរួមពិភាក្សាលើការវិនិយោគបង្កើតរោងចក្រកែច្នៃស្បែកសត្វ (ស្បែកក្របី គោ ក្របី)។

## ១៦ ការងារអប់រំ បណ្ដុះបណ្ដាលកសិកម្ម

### ១៦.១ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៨-២០១៩ សរុបចំនួន ៣ ០៥២នាក់ ចែកចេញជា ១០មហាវិទ្យាល័យគឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមសម្រាប់ការបណ្ដុះបណ្ដាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

- បានដឹកនាំនិស្សិតចុះកម្មសិក្សា អប់រំប្រជាជន និងសិស្សានុសិស្សសាលាបឋមសិក្សានៅក្នុងខេត្តពោធិ៍សាត់ ស្ដីពីជំងឺឆ្កែឆ្កួត ជំងឺផ្ដាសាយបក្សី ជំងឺញ្ញូកាស ប្រព័ន្ធជីវសុវត្ថិភាពក្នុងការចិញ្ចឹមសត្វ និង ជួយចាក់វ៉ាក់សាំងជំងឺឆ្កែឆ្កួតដល់សត្វឆ្កែ និងឆ្មា

- បានដឹកនាំនិស្សិតចុះកម្មសិក្សាស្ដីអំពីផលិតកម្មដំណាំកសិកម្មនៅក្នុងខេត្តសៀមរាប

- បានរៀបចំកិច្ចប្រជុំបើកដំណើរការគម្រោងថ្មីស្ដីពី OIE Veterinary Education Twinning Project ដែលជាកិច្ចសហការរវាងមហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ និងសាកលវិទ្យាល័យតូក្យូ។ គម្រោងនេះនឹងជួយអភិវឌ្ឍន៍មហាវិទ្យាល័យ-វេជ្ជសាស្ត្រសត្វឱ្យមានកម្មវិធីត្រឹមត្រូវ និងមានគ្រូបង្រៀនមានគុណវឌ្ឍគ្រប់គ្រាន់តាមស្តង់ដារអន្តរជាតិ OIE

- រៀបចំសិក្ខាសាលាស្ដីពីជំងឺប៉េសជ្រូកអាហ្វ្រិក (African swine fever) ឧទ្ទេសនាមដោយសាស្ត្រាចារ្យ Colin និងនិស្សិតបរទេសមកពីសាកលវិទ្យាល័យ ម៉ែលប៊ន ប្រទេសអូស្ត្រាលីជូននិស្សិតមហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ

- បានរៀបចំសិក្ខាសាលាស្ដីពី Capacity Building of Veterinary Education ពាក់ព័ន្ធនឹងទ្រឹស្ដីនិងការអនុវត្តក្នុងមន្ទីរពិសោធន៍រោគសាស្ត្របក្សី បារាសិតបក្សី និងគ្លីនិកសត្វតូច ជូនដល់មន្ត្រីសាស្ត្រាចារ្យ និងនិស្សិតក្នុងមហាវិទ្យាល័យ ដោយមានគ្រូឧទ្ទេសនាមសាធារណរដ្ឋកូរ៉េ ជប៉ុន ឥណ្ឌូនេស៊ី និង ម៉ាឡេស៊ី

- បានចុះអនុស្សរណៈយោគយល់ជាមួយអង្គការ Swiss contact និងសាក្សីដោយថ្នាក់ដឹកនាំសាកលវិទ្យាល័យ ក្នុងគោលបំណងជួយអភិវឌ្ឍន៍កម្មវិធីសិក្សារបស់មហាវិទ្យាល័យ និង បង្កើនការយកចិត្តទុកដាក់លើគុណភាពកម្មសិក្សារបស់និស្សិត

- បានរៀបចំពិធីអបអរសាទរទិវានារីអន្តរជាតិ៨មីនា និងពិធីបំពាក់គ្រឿងឥស្សរិយយស្សជូនដល់មន្ត្រីសាស្ត្រាចារ្យ

បុគ្គលិក កម្មករ។

**១៦.២ សាលាជាតិកសិកម្មព្រែកលៀប**

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៨-២០១៩ សរុបចំនួន ៩៩៣នាក់ (ស្រី៤១៩នាក់) លើជំនាញៈ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី

- បានរៀបចំសិក្ខាសាលាចំនួន ១លើក និងចូលរួមសិក្ខាសាលា ៩លើក

- ធ្វើការបណ្តុះជាលិកាផ្កាអ័រគីដេ និងចេកអំបូងពណ៌លឿងរបស់ជប៉ុនក្នុងមន្ទីរពិសោធន៍ ដាំពិសោធន៍ចេកក្រមួន ចេកស្វែង និងដាំពោតផ្អែមនាំមកពីប្រទេសជប៉ុន

- ធ្វើការពិសោធន៍គោសាច់ចំនួន ១៦ក្បាល

- រៀបចំទីតាំងពិសោធន៍ចិញ្ចឹមត្រី និងកំពឹស

- បន្តសហការជាមួយក្រុមហ៊ុនកូរ៉េ និងជប៉ុន ជំរុញលើការស្រាវជ្រាវបណ្តុះជាលិកា និងដំណាំចេក

- បន្តសហការជាមួយក្រុមហ៊ុនចិន ពិសោធន៍លើការចិញ្ចឹមត្រីនាគ បបែល និងត្រី Symphysodon។

**១៦.៣ សាលាជាតិកសិកម្មកំពង់ចាម**

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៨-២០១៩ សរុបមានចំនួន ៦៥៩នាក់ (ស្រី២៩៦នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានរៀបចំពិសោធន៍ជីសរីរាង្គលើការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- បានរៀបចំសាកល្បងផលិតមេជី Lacto Bacellus និងពិសោធន៍ឥទ្ធិពលមេជីលើការលូតលាស់ដំណាំស្ពៃក្តោប និងស្រូវនៅស្រុកកំពង់សៀម ខេត្តកំពង់ចាម

- ពិសោធន៍ប្រៀបធៀបការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហម

- បន្តការងារមន្ទីរពិសោធន៍ចិញ្ចឹម និងភ្ញាស់ជង្ហុវនាងព្រៃ

- បានសហការជាមួយលោកសាស្ត្រាចារ្យ KIM SUN MOON មកពីសាកលវិទ្យាល័យជាតិកាង វ៉ុង ចុះធ្វើការស្រាវជ្រាវប្រភេទរុក្ខជាតិនៅកម្ពុជា និងសហការរៀបចំសិក្ខាសាលាស្តីពីការរៀបចំសំណាក់ និងចម្រាញ់ប្រេងរុក្ខជាតិចេញពីម្រេចបង្កើតជាទឹកអប់

- ចែកក្រុមនិស្សិត និងគ្រូចំនួន ៣ក្រុមធ្វើការស្រាវជ្រាវអំពីការកែច្នៃកសិផល (ស្វាយចន្ទី ដំឡូងមី និងដូង) សម្រាប់ចូលរួមប្រកួតប្រជែងពានរង្វាន់ឆ្នោតមាសនៃគម្រោងមូលនិធិគីណាល់

- បានបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍ និងវិភាគបាក់តេរីនៅវិទ្យាស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ

- បានសហការជាមួយអង្គការ OISCA បញ្ជូននិស្សិតបញ្ចប់ការសិក្សាចំនួន ១នាក់ទៅបន្តការសិក្សាឯកទេសកសិកម្មសរីរាង្គ និងការបង្កាត់ជង្ហុវនាងព្រៃនៅប្រទេសជប៉ុនរយៈពេល១ឆ្នាំ។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងនៅទូទាំងប្រទេសបានបញ្ចប់ជាស្ថាពរសម្រេចបានចំនួន ៥៩៦ ៤៨៣ហ.ត ស្មើនឹង១៣៣,២៩% នៃផែនការ ៤៤៧ ៥០០ហ.ត។ ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបានចំនួន ៤៧៨ ៨២៣ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ២ ១៥០ ១០៨តោន លើសឆ្នាំមុនចំនួន ៨៧៥ ៧២៦តោន និងទិន្នផលគិតជាមធ្យម ៤,៤៩០តោន/ហ.ត។ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើយន្តការ និងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការតាមដានវាយតម្លៃអំពីការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។ ក្រសួងបានសហការជាមួយស្ថាប័នពាក់ព័ន្ធមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ចេញសេចក្តីណែនាំការការពារភ្លើងឆេះព្រៃ ការស្តុកទឹកទុក។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួង

ក៏បានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ ព្រមទាំងពង្រឹងស្មារតីទទួលខុសត្រូវក្នុងការឆ្លើយតបឲ្យបានទាន់ពេលវេលាលើមូលបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងសារព័ត៌មាននិងបណ្ដាញសង្គមផ្សេងៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្ដាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗ និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្មក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអន្តរស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្ដូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗប្រកបដោយមោទនភាព ពិតមែនតែនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណនិងគុណភាពតាមផែនការកំណត់ក្នុងឆ្នាំ២០១៨-២០១៩ ជាពិសេសនៅតំបន់ភូមិ-សាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- រៀបចំឱ្យមានកិច្ចប្រជុំការងារគ្រឿងយន្តកសិកម្មជាមួយក្រុមហ៊ុនឯកជន និងផ្នែកពាក់ព័ន្ធនានា
- ត្រៀមរៀបចំបង្កើតផែនទីវិភាគអំពីសហគមន៍កសិកម្មទូទាំងប្រទេស
- បន្តរៀបចំផែនការការងារដើម្បីធ្វើចម្ការបង្ហាញលើការគ្រប់គ្រងដីជាតិដីតំបន់ខ្ពង់រាប នៅខេត្តកោះកុង កំពង់ចាម មណ្ឌលគិរី និងខេត្តរតនគិរី សរុបចំនួន ១០ទីតាំង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាននិងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផល និងការរៀបចំកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ដើម្បីពិនិត្យអំពីវឌ្ឍនភាព បញ្ហាប្រឈម និងការលើកទិសដៅអនុវត្តបន្ត
- បន្តណែនាំដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់សហការជាមួយអាជ្ញាធរមូលដ្ឋានចុះធ្វើអន្តរាគមន៍ ដើម្បីស្វែងរកដំណោះស្រាយទប់ស្កាត់ការធ្លាក់ចុះថ្លៃកសិផល និងទីផ្សារកសិផលជាយថាហេតុ
- យកចិត្តទុកដាក់គិតគូរផ្សព្វផ្សាយអំពីការប្រើប្រាស់ជីកសិកម្ម ថ្នាំកសិកម្ម និងសារធាតុគីមីផ្សេងៗទៅលើផលិតផលកសិកម្មដែលនាំឲ្យប៉ះពាល់សុខុមាលភាពសាធារណៈ ការនាំចេញកសិផលទៅក្រៅប្រទេស និងលើកកម្ពស់ផលិតកម្មកសិកម្មសរីរាង្គ
- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ
- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទ និងរោងចក្រកែច្នៃកៅស៊ូ
- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ និងធ្វើការវិភាគសេដ្ឋកិច្ចក៏ដូចជាការបញ្ជ្រាបអំពីតម្លៃកៅស៊ូនៅលើទីផ្សារក្នុងកាលៈទេសៈបច្ចុប្បន្ននេះផងដែរ។

## ២ ផ្នែកផលិតកម្មនិងបសុព្យាបាល

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទរួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- កំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពី នីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសនៃការនាំចូល នាំចេញ ឆ្លងកាត់ ផលិតលាយផ្សំ វេចខ្ចប់ជាថ្មី ធ្វើសន្និធិ ផ្គត់ផ្គង់ចែកចាយ លក់ដុំលក់រាយ និងការដឹកជញ្ជូនបសុឱសថ

- បន្តរៀបចំសេចក្តីព្រាងស្តីពីវិធាន នីតិវិធីចុះបញ្ជីចំណីសត្វ និងបសុឱសថ ព្រមទាំងកិច្ចការសម្រួលពាណិជ្ជកម្មដល់វិស័យឯកជន

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស ព្រមទាំងជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកក្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តតាមដានស្ថានភាពជំងឺស្ទូណ្ទសជាប្រចាំនៅតាមរាជធានី-ខេត្ត

- ចុះធ្វើអង្កេត តាមដាន ស្រាវជ្រាវ យកវត្ថុវិភាគ និងស្រង់ពត៌មានជំងឺឆ្លងសត្វ។

## ៣ ផ្នែកព្រៃឈើ

- ពង្រឹងការអនុវត្តតួនាទីភារកិច្ចតាមប្រកាសលេខ ៦០២ ប្រក.កសក.ប ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាន វិទ្យាស្ថាន និងឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ

- ចុះពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបកស្រាយគម្របព្រៃឈើឆ្នាំ២០១៨ ធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងព្រៃសហគមន៍ សហការជាមួយអង្គការដៃគូដើម្បីពង្រឹងការរៀបចំ និងអនុវត្តកម្មវិធីសហគមន៍ព្រៃឈើ

- បង្កើនសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋានលើប្រព័ន្ធបច្ចេកទេសប្រព័ន្ធភូមិសាស្ត្រ (GIS) និងប្រព័ន្ធកំណត់ទីតាំងលើផែនដី (GPS)

- បន្តសហការជាមួយរដ្ឋបាលព្រៃឈើមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធដើម្បីចុះស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរសត្វព្រៃ និងបន្តប្រមូលព័ត៌មាន ជំរុញការចុះបញ្ជិកានៃការចិញ្ចឹមសត្វព្រៃជាលក្ខណៈគ្រួសារ សួនសត្វ និងកសិដ្ឋាននៅតាមបណ្តារាជធានី-ខេត្ត

- បន្តសហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាដើម្បីសិក្សាស្រាវជ្រាវ ថែរក្សា និងអភិរក្សសត្វព្រៃ ជីវចម្រុះ និងចុះផ្សព្វផ្សាយការទប់ស្កាត់ការជួញដូរសត្វព្រៃ សារសំខាន់សត្វព្រៃ និងច្បាប់ស្តីពីព្រៃឈើ

- បន្តចុះតាមដានត្រួតពិនិត្យផ្ទៀងផ្ទាត់លើការងារពាក់ព័ន្ធការកាប់រានដីព្រៃឈើ ចូលរួមសហការការងារជាមួយអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងផ្ទៀងផ្ទាត់សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ កាប់រានដីព្រៃ និងវត្ថុតាងនៃបទល្មើសព្រៃឈើ

- ចុះសិក្សាទីតាំងត្រៀមសម្រាប់ប្រារព្ធពិធីរុក្ខទិវាថ្នាក់ជាតិឆ្នាំ២០១៩ និងបន្តជំរុញការងារបណ្តុះកូនឈើសម្រាប់ចែកចាយដល់កសិករដាំអាស្រ័យផល និងចុះសិក្សាទីតាំងដីសម្រាប់បង្កើតជាស្ថានីយ និងចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ

- បន្តការងារស្រាវជ្រាវក្រពើភ្នំ និងបង្រៀនប្រជាសហគមន៍ពីបច្ចេកទេសកសិកម្ម និងការចិញ្ចឹមសត្វ

- បន្តលើកផែនការយុទ្ធសាស្ត្រក្នុងការគ្រប់គ្រង និងអភិវឌ្ឍឧស្សាហកម្មព្រៃឈើ និងការប្រើប្រាស់ផល អនុផលព្រៃឈើប្រចាំឆ្នាំ និង៥ឆ្នាំ

- សម្របសម្រួល និងបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយដៃគូអភិវឌ្ឍ និងអាស៊ាន និងអង្គការពាណិជ្ជកម្ម

ពិភពលោកតាមដានការអនុវត្តកិច្ចព្រមព្រៀងអនុស្សរណៈ អនុសញ្ញាជាតិដែលពាក់ព័ន្ធវិស័យព្រៃឈើ

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជាលេខ០១ និង០២ របស់រាជរដ្ឋាភិបាល និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។

## ៤ ផ្នែកជលផល

- បន្តការផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធអនុសាសន៍៧ចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៩ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី កង្កែប បង្គាក្តាម ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការគ្រប់គ្រងលើការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោឱ្យបានសមស្របតាមវិធានបច្ចេកទេស ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

## ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម ដើម្បីសុខុមាលភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តសកម្មភាពការងារបង្កើតទម្រង់បន្ថែមលើប្រព័ន្ធគេហទំព័រភូមិសាស្ត្រកសិកម្ម និងរៀបចំទម្រង់នៃការបញ្ចូលទិន្នន័យព័ត៌មាន ទីតាំងប្រមូលទិញ ទីតាំងលក់ រោងម៉ាស៊ីនកិនស្រូវ ដែលតម្រូវឲ្យ Admin Page បញ្ចូលព័ត៌មានសំខាន់ៗ

- ធ្វើការកែលម្អសេវាសាធារណៈច្រកចេញចូលតែមួយរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទប្រកបដោយតម្លាភាពនិងទាន់ពេលវេលា ការផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ ព្រមទាំងការបញ្ចូលសកម្មភាពយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់ៗតាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំង

ការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- បន្តសហការរៀបចំច្បាប់ផ្សេងៗ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងក្របខ័ណ្ឌកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់តាមបែបវិមជ្ឈការនិងវិសហមជ្ឈការនៅតាមអង្គភាពក្រោមឱវាទតាមការចាំបាច់ និងលំដាប់អាទិភាព

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា ហើយក៏ជាយន្តការមួយរួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជា ពីកសិកម្មបែបវិបុលវប្បកម្មដែលមានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលអាកាសធាតុ ស្តង់ដារ ពិសេសការបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម។

ថ្ងៃ [illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**